# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាចូលឆ្នាំវៀតណាម
# ថ្ងៃធំ ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៩
# ព្រះយេស៊ូប្រទានសេចក្តីសុខសាន្តឲ្យយើង

**អត្ថបទទី១៖ អេសាយ ១១,១-១០**

ចចក និងកូនចៀម នឹងរស់នៅជាមួយគ្នា ខ្លារខិននឹងដេកជាមួយកូនពពែ។ កូនគោ និងកូនសិង្ហ នឹងស៊ីចំណីជាមួយគ្នា ហើយមានក្មេងតូចម្នាក់ឃ្វាលវា។ អស ១១,៦

**អត្ថបទទី២៖ កូឡូស ៣,១២-១៧**

ត្រូវចេះទ្រាំទ្រគ្នាទៅវិញទៅមក ហើយប្រសិនបើបងប្អូនណាម្នាក់មានរឿងអ្វីមួយនឹងម្នាក់ទៀត ត្រូវតែអត់ទោសឲ្យគ្នាទៅវិញទៅមក។ ព្រះអម្ចាស់បានអត់ទោសឲ្យបងប្អូនយ៉ាងណា ចូរអត់ទោសឲ្យគ្នាទៅវិញទៅមកយ៉ាងនោះដែរ។ កូឡ ៣,១៣

**ដំណឹងល្អ៖ យ៉ូហាន ១៤,២១-៣១**

អ្នកណាមានវិន័យរបស់ខ្ញុំ និងប្រតិបត្តិតាម គឺអ្នកនោះហើយដែលស្រឡាញ់ខ្ញុំ។ ព្រះបិតារបស់ខ្ញុំស្រឡាញ់អ្នកដែលស្រឡាញ់ខ្ញុំ ហើយខ្ញុំក៏ស្រឡាញ់អ្នកនោះដែរ ខ្ញុំនឹងបង្ហាញឲ្យអ្នកនោះស្គាល់ខ្ញុំថែមទៀតផង។ យហ ១៤,២១

បងប្អូនជាទីស្រឡាញ់!

ប៉ុន្មានថ្ងៃយើងបានឃើញនៅតាមផ្ទះ នៅតាមហាងគេបានរៀបចំមានជ្រូក មានមាន់ មានទា មានបាយ មានស្រា មានអាំងប៉ាវដើម្បីសែន។ ប៉ុន្តែ ខ្ញុំបានឃើញរបៀបយើងដែលជាគ្រីស្តបរិស័ទដែលចូលនៅក្នុងឆ្នាំថ្មី យើងបានផ្ញើជីវិតរបស់ទៅលើព្រះនាងម៉ារី ទៅលើសន្តយ៉ូសែប និងទៅលើព្រះយេស៊ូដែលជាជីវិតរបស់យើងពិត។ ថ្ងៃនេះ ខ្ញុំមានអំណរសប្បាយមកអភិបូជាជាមួយបងប្អូនទាំងអស់នៅទីនេះ សូមព្រះជាម្ចាស់ប្រទានពរដល់បងប្អូនទាំងអស់នៅក្នុងឆ្នាំថ្មីនេះ យើងមានកម្លាំងកាយកម្លាំងចិត្ត ពោរពេញដោយសេចក្តីស្រឡាញ់និងសេចក្តីសុខសាន្ត ដើម្បីរស់នៅជាមួយព្រះយេស៊ូនិងធ្វើជាសាក្សីនៃសេចក្តីស្រឡាញ់របស់ព្រះអង្គ។

**ចំណុចទី១** ដែលខ្ញុំចង់ជូនសម្រាប់ឆ្នាំថ្មីនេះ **ឲ្យយើងចេះរួមរស់ដោយសហការគ្នាដោយគោរពគ្នាទៅវិញទៅមក** ទោះបីយើងជាមនុស្សខុសៗគ្នា ទោះបីយើងមានគំនិតផ្សេងៗពីគ្នា យើងអាចនៅជាមួយគ្នា។ ដូចយើងបានស្តាប់ក្នុងអត្ថបទទីមួយថ្ងៃនេះ **យើងមានសត្វចចកនៅជាមួយសត្វចៀម យើងមានសត្វសាហាវនៅជាមួយសត្វបរិសុទ្ធ**។ ថ្ងៃនេះ ជាឱកាសមួយដើម្បីសុំព្រះជាម្ចាស់ជួយយើង ដើម្បីក្នុងឆ្នាំថ្មីនេះយើងចេះសហការគ្នា យើងចេះស្រឡាញ់គ្នា យើងចេះគោរព

គ្នាទៅវិញទៅមក ទោះបីយើងមានគំនិតខុសៗគ្នា ទោះបីយើងមានរបៀបខុសៗគ្នា ប៉ុន្តែឲ្យយើងធ្វើជាសាវ័ករបស់ព្រះយេស៊ូយ៉ាងពិតប្រាកដមែន។

**ចំណុចទី២** ដូចយើងបានស្តាប់នៅក្នុងអត្ថបទព្រះគម្ពីរដំណឹងល្អ **ឲ្យយើងរស់នៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ "អ្នកណាស្រឡាញ់ខ្ញុំ អ្នកនោះនឹងប្រព្រឹត្តតាមពាក្យខ្ញុំ"**។ កុំឲ្យយើងភ្លេចអត្ថបទដែលយើងស្តាប់ពីថ្ងៃអាទិត្យ ដែលបានរំលឹកយើងអ្វីដែលសំខាន់បំផុតនៅក្នុងជីវិតរបស់យើងដែលជាគ្រីស្តបរិស័ទ ពិតមែនឲ្យយើងសេចក្តីសង្ឃឹម ពិតមែនឲ្យយើងមានជំនឿ ប៉ុន្តែប្រសិនបើយើងខ្វះសេចក្តីស្រឡាញ់ អ្វីៗទាំងអស់ដែលយើងធ្វើគ្មានតម្លៃទេ។ ឲ្យសេចក្តីស្រឡាញ់យាងចូលនៅក្នុងខ្លួនរបស់យើង ដើម្បីបង្កើតទំនាក់ទំនងរវាងគ្នានឹងគ្នា និងដើម្បីរស់នៅប្រកបដោយសេចក្តីសុខសាន្តជាមួយព្រះជាម្ចាស់ជាប្រចាំ។ យើងជាគ្រីស្តបរិស័ទ ព្រះជាម្ចាស់បានជ្រើសរើសយើង ដើម្បីធ្វើជាបុត្រធីតារបស់ព្រះជាម្ចាស់ ព្រះជាម្ចាស់បានជ្រើសរើសយើង ដើម្បីឲ្យយើងទៅជាសញ្ញានៃធម៌មេត្តាករុណារបស់ព្រះអង្គ នៅក្នុងសង្គមយើងបច្ចុប្បន្ននេះ។ សម្រាប់យើងដែលរស់នៅជ្រៃធំនេះ ក៏ជាឱកាសមួយដែរ សព្វថ្ងៃនេះយើងឃើញមានជនជាតិចិនដែលមកច្រើន មានអាគារថ្មីៗ យើងមានកាស៊ីណូច្រើនឡើងៗ។ ប៉ុន្តែពេលយើងមកលេងនៅកាស៊ីណូ ពេលយើងមកលេងនៅខារ៉ាអូខេ **តើយើងទៅរកអ្វីនៅក្នុងជីវិតរបស់យើង? តើយើងទៅរកពន្លឺអ្វីខ្លះនៅក្នុងជីវិតរបស់យើង?** សម្រាប់យើង យើងដឹងហើយពន្លឺនៅក្នុងជីវិតរបស់យើង គោលដៅនៅក្នុងជីវិតរបស់យើង គឺនៅទីនេះជាមួយព្រះយេស៊ូ ពីថ្ងៃព្រះយេស៊ូប្រសូត ព្រះយេស៊ូបានសោយព្រះទិវង្គត និងព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ គឺព្រះពន្លឺសម្រាប់ជីវិតរបស់យើង។ ពន្លឺនេះ គឺមកពីសេចក្តីស្រឡាញ់ដែលព្រះជាម្ចាស់មានចំពោះយើង ប៉ុន្តែសម្រាប់មនុស្សទាំងអស់នៅក្នុងពិភពលោកទាំងមូល ដោយសារកុំឲ្យយើងភ្លេចពីថ្ងៃដែលយើងបានគោរពបុណ្យព្រះយេស៊ូប្រសូត ព្រះយេស៊ូមិនបានប្រសូតសម្រាប់យើងដែលជាគ្រីស្តបរិស័ទប៉ុន្តែសម្រាប់មនុស្សទាំងអស់។ សព្វថ្ងៃ ព្រះយេស៊ូត្រូវការយើងដើម្បីឲ្យយើងទៅជាពន្លឺ ទៅជាសញ្ញា សម្រាប់បងប្អូនឯទៀតៗបង្ហាញថាជីវិតផ្សេងពីប្រមូលលុយទៅលេងនៅកាស៊ីណូ ឬកន្លែងមិនល្អផ្សេងៗ។ ជីវិតរបស់យើងមានតម្លៃ ដោយសារយើងដឹងថាព្រះជាម្ចាស់ស្រឡាញ់យើងទាំងអស់គ្នា។

**ចំណុចទីបី ឲ្យយើងទៅជាគ្រួសារដែលពោរពេញដោយសេចក្តីសុខសាន្ត** ដូចយើងស្តាប់នៅក្នុងអត្ថបទគម្ពីរថ្ងៃនេះ **ព្រះយេស៊ូប្រទានសេចក្តីសុខសាន្តឲ្យយើង** មិនមែនសេចក្តីសុខសាន្តតាមលោកិយ គឺសេចក្តីសុខសាន្តមកពីព្រះជាម្ចាស់ផ្ទាល់។ ខ្ញុំជូនពរបងប្អូនទាំងអស់ ដើម្បីឲ្យយើងទៅជាគ្រួសារពោរពេញដោយសេចក្តីសុខសាន្ត។ ខ្ញុំចូលចិត្តមកថ្វាយអភិបូជានៅព្រះវិហារជ្រៃធំនេះ ពេលខ្ញុំឃើញបងប្អូនអង្គុយ ខ្ញុំឃើញមហាគ្រួសារមួយ យើងមានកូនក្មេង យើងមាន

យុវជន យើងមានមីង យើងមានពូ យើងមានយាយ យើងមានតា ពេលយើងឃើញនេះ យើងជាគ្រួសារមួយពិសេស គឺគ្រួសាររបស់ព្រះជាម្ចាស់។ យើងមានកូនក្មេងរហូតដល់លោកតាលោកយាយ យើងដឹងថាយើងអង្គុយរួមជាមួយគ្នា ដើម្បីបង្ហាញអំពីសេចក្ដីសុខដែលយើងបានទទួលពីព្រះជាម្ចាស់ផ្ទាល់។ ក្មេងៗ ត្រូវតែគោរពស្ដាប់ឪពុកម្ដាយនឹងលោកតាលោកយាយ ហើយលោកតាលោកយាយត្រូវតែអប់រំកូនក្មេង ឲ្យគេរស់នៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាប្រចាំ។ ពេលយើងជាកូនក្មេងយើងស្ដាប់ឪពុកម្ដាយ ពេលយើងជាយុវជនយុវនារីជួនកាលយើងវង្វេងផ្លូវ ប៉ុន្តែត្រូវការធ្វើយ៉ាងម៉េចដើម្បីនឹងឃើញយើងបានទទួលជីវិតពីឪពុកម្ដាយ ពីលោកតា លោកយាយ ពីព្រះជាម្ចាស់ ឲ្យយកចិត្តទុកដាក់រស់នៅដើម្បីបង្កើតគ្រួសារដ៏សុខសាន្តនៅក្នុងព្រះសហគមន៍ផង និងនៅក្នុងសង្គមផង។

សូមព្រះជាម្ចាស់គង់នៅជាមួយយើង សម្រាប់ឆ្នាំថ្មីនេះ ដែលណែនាំឲ្យយើងត្រូវការគិតសារជាថ្មី ទោះបីយើងជាក្មេងក្ដី ចាស់ក្ដី យើងដឹងថាពេលយើងចូលនៅក្នុងឆ្នាំថ្មី យើងទទួលកម្លាំងថ្មី ដើម្បីរស់នៅជាគ្រីស្តបរិស័ទយ៉ាងពិសេស គ្រីស្តបរិស័ទដែលស្រឡាញ់ ដែលលោកលែងទោស និងដែលជាសញ្ញាសម្គាល់នៃសេចក្ដីសុខ។ សម្រាប់ឆ្នាំថ្មីនេះ ឲ្យយើងទុកព្រះបន្ទូលរបស់ព្រះយេស៊ូ កុំឲ្យយើងភ័យខ្លាចឲ្យសោះ ដោយសារយើងដឹងថាជីវិតរបស់យើងមានតម្លៃមានអត្ថន័យ មានគោលដៅ គឺព្រះយេស៊ូដែលរស់នៅជាមួយយើង ដែលធ្វើដំណើរជាមួយយើងពីមួយថ្ងៃទៅមួយថ្ងៃ ណែនាំឲ្យយើងរស់នៅក្នុងព្រះពររបស់ព្រះជាម្ចាស់។ សម្រាប់ឆ្នាំនេះ ពាក្យចុងក្រោយខ្ញុំសូមចម្រើនពរដល់បងប្អូនទាំងអស់ មានន័យថាឲ្យយើងពោរពេញដោយព្រះពរមកពីព្រះជាម្ចាស់។ ជយោឆ្នាំថ្មី! អាម៉ែន៕